# ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់ខែសីហា ឆ្នាំ២០០៧

**មតិម្ចាស់ឆ្នោត: "ខ្ញុំជារាស្ត្រនឹងយកអំណាចរបស់ខ្ញុំមកដាក់ក្នុងដៃវិញ បើអ្នកតំណាងរាស្ត្រមិនចុះជួបសួរសុខទុក្ខដោះស្រាយបញ្ហាជូនរាស្ត្រនោះទេ"**

នៅខណៈដែលដំណើរការសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោតដើម្បីត្រៀមលុបឈ្មោះអ្នកបោះឆ្នោតដែលបានស្លាប់ ផ្លាស់ទីលំនៅ គ្មានទីលំនៅអចិន្ត្រៃយ៍ក្នុងឃុំ/សង្កាត់ មានឈ្មោះស្ទួន ឬជាជនអន្តោប្រវេសន៍ចេញពីបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០០៦ បានចាប់ផ្តើមតាំងពីខែកក្កដាមក ភាពមិនប្រក្រតីនានាបានកើតឡើងបានធ្វើឱ្យម្ចាស់ឆ្នោតផ្ទាល់មានការភ័យខ្លាចអំពីការបាត់បង់សិទ្ធិក្នុងការបោះឆ្នោត ហើយទាមទារឱ្យអ្នកតំណាងរាស្ត្រយកចិត្តទុកដាក់ចំពោះបញ្ហានេះដែលម្ចាស់ឆ្នោតកំពុងប្រឈម បើអ្នកតំណាងរាស្ត្រចង់ទទួលបានសម្លេងឆ្នោត។

ម្ចាស់ឆ្នោតឈ្មោះ **យី** រស់នៅ ស្រុកគីរីវង់ ខេត្តតាកែវបាននិយាយថា: *"ខ្ញុំជាម្ចាស់ឆ្នោត ខ្ញុំបានប្រគល់អំណាចដល់អ្នកតំណាងរាស្ត្រដែលធ្វើការតំណាងខ្ញុំ។ តែខ្ញុំបានសង្កេតឃើញថាតំណាងរាស្ត្រនេះ មិនបានធ្វើការជិតដល់ចំពោះខ្ញុំជារាស្ត្រទេ។ ខ្ញុំតែងតែទន្ទឹងមើលលោកមកសួរសុខទុក្ខ និងមើលខ្ញុំថាតើខ្ញុំមានបញ្ហាអ្វី...ខ្ញុំជារាស្ត្រនឹងយកអំណាចរបស់ខ្ញុំមកដាក់ក្នុងដៃវិញ បើអ្នកតំណាងរាស្ត្រមិនចុះជួបមកសួរសុខទុក្ខ ដោះស្រាយបញ្ហាជូនរាស្ត្រនោះទេ។"*

ម្ចាស់ឆ្នោតរូបនេះបានបញ្ចេញមតិបែបនេះ នៅក្នុងកម្មវិធីវិទ្យុសម្លេងសង្គមស៊ីវិល នៅពេលដែលបងប្អូនរបស់គាត់ពីរនាក់មិនបានបោះឆ្នោតឃុំ/សង្កាត់ហើយគាត់មានការភ័យខ្លាចថាឈ្មោះរបស់ពួកគេអាចត្រូវបានគេលុបចេញ ដោយសារតែមិនឃើញមានបិទបញ្ជីឈ្មោះគ្រោងនឹងលុបចេញតាមពេលកំណត់នៅក្នុងឃុំរបស់គាត់ ។

## ការចុះទៅកាន់មណ្ឌលនានារបស់អ្នកតំណាងរាស្ត្រ

នៅក្នុងខែសីហានេះ មានតែការប្រជុំនៅក្នុងគណៈកម្មការជំនាញ និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាប៉ុណ្ណោះ តែមិនមានការប្រជុំពេញអង្គទេ ដោយរដ្ឋសភានៅតែបន្តវិស្សមកាលរបស់ខ្លួន។ ក្នុងឱកាសសំរាកវិស្សមកាលនេះ ខុមហ្វ្រែលទទួលបានព័ត៌មានថា មានអ្នកតំណាងរាស្ត្រយ៉ាងហោចណាស់ចំនួន **៥០រូប** បានចុះបេសកកម្មយ៉ាងតិចចំនួន **១៧០**លើក ក្នុងមណ្ឌលចំនួន **២១**។

ក្រាហ្វិចទី១: ភាគរយអ្នកតំណាងរាស្ត្រចុះបេសកកម្ម នៃគណបក្សនីមួយៗធៀបនឹងគណបក្សរបស់ខ្លួន




ក្នុងរយៈពេលមួយខែនេះ អ្នកតំណាងរាស្ត្រ មកពីគណបក្សនយោបាយទាំងបីសរុបចំនួន **៥០រូប** បានចុះបេសកកម្មទាំងក្នុងមណ្ឌល និងក្រៅមណ្ឌលចំនួន **១៧០លើក** ក្នុងគោលបំណងចុះ**ជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ចូលរួមក្នុងវេទិកា ចុះអមដំណើរថ្នាក់ដឹកនាំ ចុះពង្រឹងបណ្តាញគណបក្ស** និងជាពិសេសចុះ**សួរសុខទុក្ខនិងចែកអំណោយ**នៅក្នុងមណ្ឌលចំនួន ២១។ ក្នុងនោះ **មណ្ឌលបាត់ដំបង** នៅតែមានអ្នកតំណាងរាស្ត្រចុះច្រើនជាងគេរហូតដល់ចំនួន ៦៣**លើក**។ ចំណែកមណ្ឌលដែលខុមហ្វ្រែលមិនបានទទួលព័ត៌មាន ឬមិនមានព័ត៌មានអំពីការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្ររួមមានមណ្ឌល **មណ្ឌលគីរី ស្ទឹងត្រែង និង ឧត្តរមានជ័យ**។ ខុមហ្វ្រែលសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រដែលបានចុះ បេសកកម្មមកពីគណបក្ស **ប្រជាជនកម្ពុជា** និងគណបក្ស **សម រង្ស៊ី** មានការធ្លាក់ចុះ បើប្រៀបនឹងខែមុន ខណៈដែលចំនួនអ្នកតំណាងរាស្ត្រមកពីគណបក្ស ហ៊្វុនស៊ិនប៉ិចមានចំនួនកើនឡើង។ ក្នុងនោះអ្នកតំណាងរាស្ត្រមកពីគណបក្ស**ប្រជាជនកម្ពុជា**បានធ្លាក់ចុះពី ៣៦រូប ក្នុងខែកក្កដា មកត្រឹម **៣០រូប** (ស្មើនឹង ៤១%នៃអ្នកតំណាងរាស្ត្រ គណបក្សនេះទាំងអស់ ដែលមានចំនួន ៧៣រូប) គណបក្ស **សម រង្ស៊ី** ពី ១៤រូប ក្នុងខែកក្កដា មក **១១រូប** (ស្មើនឹង ៤៦% នៃអ្នកតំណាងរាស្ត្រគណបក្សនេះ ទាំងអស់ដែលមានចំនួន ២៤រូប) និងគណបក្ស **ហ៊្វុនស៊ិនប៉ិច**បានឡើងពី ៥រូប ទៅ **៩រូប** (ស្មើនឹង ៣៥% នៃអ្នកតំណាងរាស្ត្រ គណបក្សនេះទាំងអស់ ដែលមានចំនួន ២៦រូប) ហើយអ្នកតំណាងរាស្ត្រ ដែលបានចុះបេសកកម្មនាំមុខគេ ក្នុងចំណោមតំណាងរាស្ត្រ

ក្នុងគណបក្សរបស់ខ្លួនរួមមាន:

- អ្នកតំណាងរាស្ត្រ **ទេស ហ៊ាញ** មណ្ឌលបាត់ដំបង មកពីគណបក្សប្រជាជនកម្ពុជា **បានចុះបេសកកម្មចំនួន ១៦លើក**
- អ្នកតំណាងរាស្ត្រ **សម រង្ស៊ី** មណ្ឌល កំពង់ចាម មកពីគណបក្ស សមរង្ស៊ី **បានចុះបេសកកម្មចំនួន ១២ លើក**
- អ្នកតំណាងរាស្ត្រ **ខៀវ សន** មណ្ឌល កណ្ដាល មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច បាន**ចុះបេសកកម្មចំនួន ៨ លើក**

| **គោលបំណងនៃការចុះបេសកកម្ម ទាំង ១៧០លើកនៃអ្នកតំណាងរាស្ត្រទាំង៥០រូប** | **គណបក្សនយោបាយ** | | | **សរុបនៃគោលបំណង** |
|---|---|---|---|---|
| | ៣០រូប | ១១រូប | ៩រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិង ការសម្ពោធសមិទ្ធផលនានា | ៥៦ | ១០ | ៩ | ៧៥ (៤៤%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្ដាញគណបក្ស | ២៥ | ១៧ | ៤ | ៤៦ (២៧%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៩ | ១០ | ៤ | ២៣ (១៤%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៦ | ៥ | ៧ | ១៨ (១០%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ៥ | ០ | ៣ | ៨ (៥%) |
| **សរុប ជាភាគរយតាមគណបក្ស** | ៩៩ (៥៨%) | ៤៧ (២៨%) | ២៤ (១៤%) | ១៧០ (១០០%) |

**តារាងទី១:** ចំនួនបេសកកម្មរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងផ្សេងៗដែលខុមហ្វ្រែលទទួលបាន

តារាងទី១ បានបង្ហាញថា:

- **ការសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា** នៅតែនាំមុខគោលបំណងផ្សេងៗទៀតបើទោះបីជាមានការធ្លាក់ចុះពី **៨២លើក** (**ក្នុងខែកក្កដា**) មកត្រឹម **៧៥លើក ស្មើនឹង៤៤%** នៃចំនួនបេសកកម្មសរុប) ក៏ដោយ។ **សកម្មភាពនេះត្រូវបានធ្វើឡើងដោយអ្នកតំណាងរាស្ត្រទាំងបីគណបក្ស តែនៅតែត្រូវបាននាំមុខដោយអ្នកតំណាងរាស្ត្រ មកពីគណបក្សប្រជាជនកម្ពុជាដដែល** ដែលមានរហូតដល់ចំនួន **៥៦លើក** ដូចជាការចុះបេសកកម្មរបស់តំណាងរាស្ត្រ មណ្ឌល កំពត **សោម ចិន** នៅភូមិតាដិប ឃុំអណ្ដូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពតកាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ ដើម្បីសំណេះសំណាលជាមួយជនជាតិខ្មែរឥស្លាម ដោយចែកខ្សែភ្លើង ចំនួន១០ដុំ និងថ្នាំសម្លាប់សត្វល្អិត (មមាចត្នោត) ចំនួន ១០០កញ្ចប់ សំរាប់ឱ្យជនជាតិខ្មែរឥស្លាមយកទៅប្រើប្រាស់។
- **ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស** ដោយអ្នកតំណាងរាស្ត្រ មានចំនួនកើនឡើងពី ៤១លើក ក្នុងខែកក្កដាដល់ **៤៦លើក ក្នុងខែសីហា ស្មើនឹង ២៧%** នៃចំនួនបេសកកម្មសរុប។ ចំនួននេះ**នៅតែនាំមុខ** ដោយអ្នកតំណាងរាស្ត្រមកពីគណបក្ស **ប្រជាជនកម្ពុជា** ដែលមានចំនួន **២៥លើក** ខណៈដែលគណបក្ស **ហ្វ៊ុនស៊ិនប៉ិច មានតែ៤លើក**។ ទោះបីយ៉ាងណា បើសង្កេតពីគោលបំណងតាមគណបក្សនយោបាយវិញឃើញថា គណបក្ស **សមរង្ស៊ី នៅតែផ្ដោតខ្លាំងទៅលើការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស** ដោយសកម្មភាពនេះមានចំនួន **១៧លើកដែល** ច្រើនជាងគោលបំណងដទៃទៀត។ ឧទាហរណ៍ដូចជាការទៅចូលរួមសមាជរបស់គណបក្សនេះដោយសមាជិកសភានានារួមមានអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** នៅខេត្តកំពង់ធំ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ជាដើម។
- **ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ** មានការធ្លាក់ចុះពី ៣៤លើក ក្នុងខែកក្កដាមកត្រឹមតែ **២៣លើក ស្មើនឹង** ១៤%នៃចំនួនបេសកកម្មសរុប។ ខុសពីខែមុនៗ ដែលសកម្មភាពនេះត្រូវបាននាំមុខដោយអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា នៅក្នុងខែសីហានេះអ្នកតំណាងរាស្ត្រមកពីគណបក្ស **សមរង្ស៊ី** បានចុះអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនច្រើនជាងគេចំនួន **១០លើក**។ ចំណែកគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលខែមុនៗមិនឃើញមានអ្នកតំណាងរាស្ត្រចុះអមដំណើរថ្នាក់ដឹកនាំសោះ តែនៅខែនេះអ្នកតំណាងរាស្ត្រមកពីគណបក្សនេះបានចុះអមដំណើរ

ថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនចំនួន **៤លើក** ដូចជាការចុះអមដំណើរប្រធានគណបក្សហ៊្វុនស៊ិនប៉ិច លោក កែវ ពុទ្ធរស្មី ដោយអ្នកតំណាងរាស្ត្រ **ខៀវ សន មណ្ឌលកណ្ដាល អ្នកអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សន្ធា មណ្ឌលព្រៃវែង អ្នកតំណាងរាស្ត្រ ស៊ឹម សូលី មណ្ឌលកំពង់ធំ** ក្នុងពិធីសំណេះសំណាលជាមួយ សមាជិក សមាជិកាបក្សចំនួន ២៤៥០នាក់ នៅខេត្តកំពង់ធំ កាលពីថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៧ ជាដើម ។

- **ការចូលរួមក្នុងវេទិកាសាធារណៈ** ដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអ្នកតំណាងរាស្ត្រចូលរួមចំនួន **១៨លើក ស្មើនឹង ១០%** នៃចំនួនបេសកកម្មសរុប ។ សកម្មភាពនេះត្រូវបានចូលរួមដោយអ្នកតំណាងរាស្ត្រមកពីគណបក្សទាំង ៣ ប្រហាក់ប្រហែលគ្នា ដោយគណបក្ស **ហ៊្វុនស៊ិនប៉ិចចំនួន ៧លើក** គណបក្ស **ប្រជាជនកម្ពុជា ៦លើក** និងគណបក្ស **សមរង្ស៊ី ៥លើក** ។ នៅថ្ងៃទី ១២ ខែ សីហា នៅខេត្តកំពង់ធំ អ្នកតំណាងរាស្ត្រទាំងបីគណបក្សរួមមានអ្នកតំណាងរាស្ត្រ **ស៊ិក ប៊ុនហុក មណ្ឌលកំពង់ធំ** អ្នកតំណាងរាស្ត្រ **ខៀវ សន មណ្ឌលកណ្ដាល** និងអ្នកតំណាងរាស្ត្រ **គឹម សួរភីរិទ្ធិ មណ្ឌលបន្ទាយមានជ័យ** បានចូលរួមជាវាគ្មិនក្នុងវេទិកាតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ នៅក្នុងខេត្តកំពង់ធំកាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៧ ។
- **ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា** ត្រូវបានអ្នកតំណាងរាស្ត្រ យកចិត្តទុកដាក់តិចជាងគេបំផុតត្រឹមតែ **៨លើក ស្មើនឹង ៥%** នៃបេសកកម្មសរុប ។ ក្នុងនោះ តំណាងរាស្ត្រមកពីគណបក្ស **សមរង្ស៊ី** ចំនួន **៥លើក** និងតំណាងរាស្ត្រមកពីគណបក្ស **ប្រជាជនកម្ពុជា** ចំនួន **៣លើក** ។ ឧទាហរណ៍កាលពីថ្ងៃទី ២៦ ខែសីហា តំណាងរាស្ត្រ **គួយ ប៊ុនរឿន** មណ្ឌលតាកែវ មកពីគណបក្ស សម រង្ស៊ី បានចុះទៅកាន់ភូមិស្រែជ័យ ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ **ដោយបានជួយសំរួល និងអន្តរាគមន៍ដល់ប្រជាពលរដ្ឋ ២៣១** គ្រួសារដែលរកស៊ីរែកខ្សាច់លក់ ប៉ុន្តែមានក្រុមហ៊ុនមួយបានយកម៉ាស៊ីនមកប៉ូមខ្សាច់ ដណ្តើមការងាររបស់ប្រជាពលរដ្ឋទាំងអស់ ។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទិនសភា និង តំណាងរាស្ត្រ

### អ្នកតំណាងរាស្ត្រ បន្តអន្តរាគមន៍ជួយដល់អតីតព្រះចៅអធិការវត្តភ្នំដិន ព្រះនាម ទឹម សាខន

ក្នុងខែសីហានេះ ខុមហ្វ្រែលសង្កេតឃើញថាអ្នកតំណាងរាស្ត្របានតាមឃ្លាំមើល និងជួយអន្តរាគមន៍ជាបន្តបន្ទាប់ករណីរឿងលោក **ទឹម សាខន** ដែលបានបាត់ខ្លួន និងក្រោយមកត្រូវបានអាជ្ញាធរវៀតណាមអះអាងថា លោក **ទឹម សាខន កំពុងជាប់ពន្ធនាគារនៅវៀតណាម** ។

នៅចុងខែសីហានេះ អ្នកតំណាងរាស្ត្រ **សុន ឆ័យ** ប្រធានគណៈកម្មការទី៥ ទទួលបន្ទុកកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនា និងព័ត៌មានរបស់រដ្ឋសភា**បានផ្ញើលិខិតទៅស្ថានទូតវៀតណាម**ដើម្បីសុំឱ្យស្ថានទូតនេះអនុញ្ញាតឱ្យ**មានការទៅសួរសុខទុក្ខអតីតសង្ឃ ទឹម សាខន** បន្ទាប់ពីកិច្ចប៉ុនប៉ងរបស់លោកដើម្បីជួបឯកអគ្គរដ្ឋទូតវៀតណាមត្រូវបានបដិសេធដោយទូតវៀតណាមលើកហេតុផលថាជាប់រវល់ ។

ដោយឡែកនៅថ្ងៃទី ១៥ ខែ សីហា **គណៈកម្មការទី៤ ទទួលបន្ទុកមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ**របស់រដ្ឋសភាបានធ្វើការប្រជុំជជែកគ្នាស្តីពីគម្រោងបេសកកម្មគណៈប្រតិភូសភាកម្ពុជាទៅកាន់ប្រទេសវៀតណាម**ដើម្បីសួរសុខទុក្ខ លោក ទឹម សាខន** ក៏ប៉ុន្តែគម្រោងនេះមិនបានសម្រេចឡើយ ដោយសារមានការអល់អែកពីតំណាងរាស្ត្រខ្លះមកពីគណបក្សកាន់អំណាច ។ អ្នកតំណាងរាស្ត្រ **អៀ លឹមសួរ** មកពីគណបក្សហ៊្វុនស៊ិនប៉ិចបានប្រាប់វិទ្យុអាស៊ីសេរីថា "*កិច្ចការរបស់តំណាងរាស្ត្រនិមួយៗមិនមែនថា យើងឯករាជ្យទេ វាមិនអាចចៀសផុតពីមេបក្សក្នុងសភានិមួយៗជាអ្នកគ្រប់គ្រងនោះទេ.. ដល់តែមានការជជែកគ្នា ដើម្បីធ្វើការទៅ កុំឱ្យមានបញ្ហាថ្ងៃក្រោយ*" ។

អ្នកតំណាងរាស្ត្រ **កែវ រ៉េមី មណ្ឌលភ្នំពេញ**នៅថ្ងៃទី ០៦ ខែ សីហា ក៏បាន**ផ្ញើលិខិតជូនរដ្ឋមន្ត្រីក្រសួងការបរទេស និងហប្រតិបត្តិការអន្តរជាតិ** ដើម្បីស្នើសុំឱ្យមាន**កិច្ចជួយអន្តរាគមន៍ទៅអាជ្ញាធរវៀតណាមបញ្ជូន លោក ទឹម សាខន** វិលត្រឡប់មកកម្ពុជាវិញ ប៉ុន្តែមិនមានព័ត៌មានស្តីពីភាពជោគជ័យនៃសំណើនេះឡើយ ។

គួរំលឹកដែរថា មុននឹងមានព័ត៌មានថា លោក **ទឹម សាខន** ត្រូវវៀតណាមចាប់ឃុំ **នៅដើមខែសីហា គណៈកម្មការទី៤** ក៏បានកោះអញ្ជើញតំណាងក្រសួងមហាផ្ទៃឱ្យចូលទៅបំភ្លឺរឿងការបាត់ខ្លួន លោក **ទឹម សាខន** ផងដែរ ។ ប៉ុន្តែតំណាងក្រសួងមហាផ្ទៃ មិនបានដឹងពីទីកន្លែងរបស់លោក ទឹម សាខនឡើយ ។

លោក **ទឹម សាខន ជាអតីតព្រះចៅអធិការវត្តភ្នំដិន** ស្ថិតនៅស្រុកគីរីវង់ ខេត្តតាកែវ ដែលមានដើមកំណើតខ្មែរក្រោម ត្រូវបានអាជ្ញាធរខ្មែរ ចាប់ផ្សឹកកាលពីចុងខែ មិថុនា ពីបទបង្កឱ្យមានការបែកបាក់ចំណងមិត្តភាព កម្ពុជា-វៀតណាម និងប្រព្រឹត្តអំពើខុសធម្មវិន័យ ។ ក្រោយពីការផ្សឹកនេះ លោក **ទឹម សាខន** បានបាត់ខ្លួនមួយរយៈ ហើយក្រសួងមហាផ្ទៃបានអះអាងថា លោកស្ម័គ្រចិត្តទៅវៀតណាមវិញ ខណៈដែលប្រភពខ្លះបានលើកឡើងថា

លោក **ទឹម សាខន** ត្រូវបានគេចាប់បង្ខំឱ្យចូលក្នុងឡាន ហើយក៏បាត់ខ្លួនរហូតទៅ។

**អ្នកតំណាងរាស្ត្រម្នាក់ទៀតនឹងបាត់បង់សមាជិកសភាដោយសារលាឈប់ពីគណបក្សនយោបាយ**

អ្នកតំណាងរាស្ត្រ **កែវ រ៉េមី** **មណ្ឌលភ្នំពេញ** មកពីគណបក្ស **សម រង្ស៊ី** នឹងត្រូវបាត់បង់សមាជិកភាពសភានៅដើមខែក្រោយក្នុងការប្រជុំវិសាមញ្ញរបស់រដ្ឋសភា ដោយហេតុផលអ្នកតំណាងរាស្ត្ររូបនេះបានលាឈប់ពីគណបក្ស **សម រង្ស៊ី** ទៅចូលរួមជាមួយគណបក្ស **សិទ្ធិមនុស្ស**។

តាមប្រភពពីគណបក្ស សម រង្ស៊ី អ្នកដែលជំនួសតំណាងរាស្ត្រ កែវ រ៉េមី គឺ លោក **នូ សុវត្ថិ**។ សម្ព័ន្ធអង្គការសង្គមស៊ីវិលធ្លាប់បានពន្យល់ថា **សិទ្ធិរបស់អ្នកតំណាងរាស្ត្រមានការចុះខ្សោយនិងស្ថិតនៅក្រោមឥទ្ធិពលនៃគណបក្សនយោបាយ** ដោយសារ **តែការអនុវត្តន៍មាត្រា១២០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ** ដែលចែងថា **សមាជិករដ្ឋសភាបាត់បង់សមាជិកភាពនៅពេលសាមីខ្លួន បាត់បង់សមាជិកភាពពីគណបក្សនយោបាយ**។

ទន្ទឹមនឹងនេះ **អង្គការសង្គមស៊ីវិល និងអ្នកតំណាងរាស្ត្រមួយចំនួនក៏បានទទូចហើយទទូចទៀតឱ្យធ្វើវិសោធនកម្មមាត្រា១២០នេះ ដោយសមាជិកភាពអ្នកតំណាងរាស្ត្រ មិនត្រូវបាត់បង់ដោយសារតែការប្រាសចាកសមាជិកភាពពីគណបក្សនយោបាយនោះទេ**។

អ្នកតំណាងរាស្ត្រកែវ រ៉េមី ក៏ធ្លាប់បានស្នើធ្វើវិសោធនកម្មមាត្រានេះដែរ ក៏ប៉ុន្តែមិនបានទទួលជោគជ័យឡើយ។

**សង្ខេបការបណ្តុះបណ្តាលនានាដល់បុគ្គលិកស្ថាប័នរដ្ឋសភា**

តាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន នៅក្នុងខែសីហានេះមានវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួនពីរត្រូវបានរៀបចំឡើងសំរាប់សមាជិកសភា និងបុគ្គលិកស្ថាប័នរដ្ឋសភា។

នៅថ្ងៃទី ៣០-៣១ ខែសីហា ឆ្នាំ២០០៧ មានវគ្គបណ្តុះបណ្តាលស្តីអំពី **"យុទ្ធសាស្ត្រនៃការលើកកម្ពស់សភា ក្នុងការផ្តល់ព័ត៌មាន និងការប្រាស្រ័យទាក់ទងរបស់សភា និងគណៈកម្មការសភាជាមួយសាធារណជន"** ដែលរៀបចំឡើងដោយគំរោងគាំទ្រទីតិបញ្ញត្តិកម្ពុជា-កាណាដា សហការជាមួយ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម **ហ៊ុល ប៊ុនថា** អគ្គលេខាធិការរងរដ្ឋសភា បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះនឹងរួមចំណែកដល់ការពង្រឹង សមត្ថភាពមន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ឱ្យយល់ដឹងកាន់តែច្បាស់ក្នុងវិស័យនេះ ។ ឯកឧត្តមបានលើកឡើងថា សេវាព័ត៌មាន គឺជាផ្នែកមួយដ៏សំខាន់សម្រាប់បម្រើការផ្សព្វផ្សាយអំពីសកម្មភាពរបស់រដ្ឋសភា និងបង្កើននូវការយល់ដឹងអំពីការងាររដ្ឋសភាដល់សាធារណជន។

ដោយឡែក នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៧ មានការប្រារព្ធសិក្ខាសាលាមួយស្តីពី **មន្ត្រីគាំទ្រសេវាការងារដល់ សមាជិក សមាជិកា រដ្ឋសភា និងអគ្គលេខាធិការដ្ឋាន** ក្រោមកិច្ចសហការរវាងរដ្ឋសភា និងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ដោយមានការអញ្ជើញចូលរួមពី សមាជិក សមាជិកា រដ្ឋសភា មន្ត្រីអគ្គលេខាធិការដ្ឋាន ភ្ញៀវ ជាតិ អន្តរជាតិ ប្រមាណ ១៥០រូប។

អ្នកតំណាងរាស្ត្រ **ញ៉ែម ថ្លាវី មណ្ឌលកំពង់ធំ**បានមានប្រសាសន៍ថា: ការបើកសិក្ខាសាលានេះ ពិតជាមានសារៈសំខាន់ណាស់ដល់ រដ្ឋសភា គឺជាវេទិកាសម្រាប់អ្នកតំណាងរាស្ត្រគ្រប់រូប បានដឹងនូវសេវាចាំបាច់របស់ខ្លួនដែលសេវានេះ អ្នកតំណាងរាស្ត្រត្រូវការបំពេញតួនាទី ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងមន្ត្រីស្ថាប័នសភាបានយល់ពីតួនាទីរបស់ខ្លួន ក្នុងការគាំទ្រសេវារបស់តំណាងរាស្ត្រងាយស្រួល ជួយលោក បំពេញការងារ ប្រកបដោយជោគជ័យ។

ទោះបីយ៉ាងណាឯកឧត្តម ឡេង ប៉េងឡុង អគ្គលេខាធិការរដ្ឋសភា បានមានប្រសាសន៍ថា នៅពេលនេះ**ចំណេះដឹងមន្ត្រីអគ្គលេខាធិការដ្ឋាននៅមានកំរិត និងខ្វះសម្ភារៈបច្ចេកទេសមួយចំនួន** ប៉ុន្តែយើងនឹងព្យាយាមធ្វើកិច្ចការនេះជាជំហាន១ រហូតទទួលបានជោគជ័យនៅថ្ងៃណាមួយមិនខាន។

ខុមហ្វ្រែល សង្ឃឹមថាក្រោយពីវគ្គបណ្តុះបណ្តាលនេះទៅ អង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងសភា នឹងទទួលបាននូវការប្រាស័យទាក់ទង និងការផ្តល់ព័ត៌មានប្រសើរ និងមានតម្លាភាពជាងមុនពីសមាជិក និងបុគ្គលិកលេខាធិការដ្ឋានរបស់រដ្ឋសភា។


*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង:*

- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល អ៊ីម៉ែល: marsophal@online.com.kh
- លោក **សុខ ពិទូរ្យ** មន្ត្រីផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០៩២ ៨៦២ ៦០២


************************************